**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ លើផ្ទៃដីចំនួន **៧.០៧៤(ប្រាំពីរពាន់ចិតសិបប្រាំបួន)**ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តរតនៈគីរី សម្រាប់ផ្ដល់ជូនក្រុមហ៊ុន FU SHENG HAI (Cambodia) Co., LTD) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ និងដំណាំផ្សេងៗ) និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ធម្មជាតិ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់មជ្ឈមណ្ឌលកំសាន្ត ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៥២០ សជណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

www.pheakdeylaw.com

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនៈគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "<u>ដើម្បីគោរពជូនជ្រាប</u>"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

បណ្ណាគារ ភក្តីឡ្ជ
PheakdeyLaw Book Store

ផែនទី ទីតាំងដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ របស់ក្រុមហ៊ុន FU SHENG HAI ( Cambodia ) CO., LTD
ស្ថិតនៅក្នុងឧទ្យានជាតិវីរៈជ័យ ឃុំមិសាស្រ្តស្រុកតាវែង និងស្រុកអណ្ដូងមាស ខេត្តរតនគីរី លើផ្ទៃដីចំនួន ៧០៧៩ ហិកតា




ផែនទី និងនិយាមការនេះ ជាឯកសារ ភ្ជាប់នឹងលិខិតលេខ ...៥៧០... សជណ
ចុះថ្ងៃទី ... ខែ ឧសភា ឆ្នាំ ២០១១

ផែនទី និងនិយាមការនេះ ជាឯកសារ ភ្ជាប់នឹងលិខិតលេខ ...
ចុះថ្ងៃទី ... ខែ ឧសភា ... ឆ្នាំ ២០១១

**សញ្ញាសំគាល់**

- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង. អូរ

| Id | N | X | Y |
|---|---|---|---|
| 1 | A | 755060 | 1559198 |
| 2 | B | 751827 | 1557238 |
| 3 | C | 749159 | 1558479 |
| 4 | D | 749397 | 1561887 |
| 5 | E | 750929 | 1565955 |
| 6 | F | 756740 | 1572426 |
| 7 | G | 755321 | 1573504 |
| 8 | H | 756217 | 1576938 |
| 9 | I | 759778 | 1579400 |
| 10 | J | 760290 | 1579297 |

www.pheakdeylaw.com